ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មានស្តីពី
# លទ្ធផលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយដៃគូសន្ទនាអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ
# ១០ កញ្ញា ២០២០ តាមប្រព័ន្ធវីដេអូ

-----------------

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ជាថ្ងៃទីពីរដែល ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ជាមួយដៃគូសន្ទនាអាស៊ាន នាឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី ៥៣ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត ។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហរដ្ឋអាមេរិក

កិច្ចប្រជុំបានពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការកន្លងមក និងបានពិភាក្សាអំពីទិសដៅអនាគតនៃទំនាក់ទំនងរវាងអាស៊ាន-សហរដ្ឋអាមេរិក។ ប្រទេសសមាជិកអាស៊ាន និងសហរដ្ឋអាមេរិកបានសម្តែងនូវសេចក្តីពេញចិត្តដែលបន្ទាត់សកម្មភាពទាំងអស់ ដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហរដ្ឋអាមេរិក ២០១៦-២០២០ ត្រូវបានអនុវត្តតាមផែនការ។

ប្រទេសសមាជិកអាស៊ានបានសម្តែងនូវការកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិក ក្នុងការគាំទ្រមជ្ឈភាពអាស៊ាន នៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងវិវត្ត ដែលបើកចំហ មានតម្លាភាព ប្រកបដោយបរិយាប័ន្ន និងដែលផ្អែកលើច្បាប់ ដោយកសាងលើយន្តការដែលដឹកនាំដោយអាស៊ាន ហើយដែលពហុភាគីនិយមនៅតែជាឧបករណ៍ប្រកបដោយប្រសិទ្ធិភាពមួយ សម្រាប់ដោះស្រាយបញ្ហាតំបន់ និងអន្តរជាតិ។ កិច្ចប្រជុំបានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងសង្គម-វប្បធម៌អាស៊ាន-សហរដ្ឋអាមេរិក ដូចជាលើវិស័យពាណិជ្ជកម្ម ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស។ ប្រទេសសមាជិកអាស៊ានបានថ្លែងអំណរគុណដល់សហរដ្ឋអាមេរិក ដែលបានចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងទន្ទឹងរង់ចាំធ្វើសហប្រតិបត្តិការកាន់តែស៊ីជម្រៅថែមទៀត ជាមួយសហរដ្ឋអាមេរិក ក្នុងការស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានរំលេចអំពីសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការដ៏ល្អដែលកំពុងកើតមាន រវាងអាស៊ាន និងអាសហរដ្ឋមេរិក តាមរយៈក្របខ័ណ្ឌទ្វេភាគី និងតំបន់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះសហរដ្ឋអាមេរិកដែលបានគាំទ្រដល់វិស័យថែទាំសុខភាព និងវត្តមានដ៏រឹងមាំនៃមជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺឆ្លង(CDC)របស់អាមេរិក ក្នុងការជួយបណ្តាប្រទេសនានាដូចជាប្រទេសកម្ពុជា នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការគាំទ្រចំពោះសេចក្តីព្រាងសេចក្តីប្រកាសរួម ស្តីពីការអភិវឌ្ឍមូលធនមនុស្ស។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានលើកទឹកចិត្តដល់សហរដ្ឋអាមេរិកឱ្យបន្តគាំទ្រកម្មវិធីទ្រទ្រង់នានាដែលមានគោលបំណងកែលម្អ និងបង្កើនជំនាញថ្មីៗបន្ថែមទៀតដល់កម្លាំងពលកម្មអាស៊ាន ដើម្បីលើកកម្ពស់ការប្រកួតប្រជែងផ្នែកឧស្សាហកម្ម នៅក្នុងតំបន់អាស៊ាន។ ការលើកស្ទួយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ប្រព័ន្ធបរិស្ថានឌីជីថល សហគ្រិនភាពស្ត្រី ការតភ្ជាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ (fintech) និងក្រុមហ៊ុនបច្ចេកវិទ្យាបង្កើតថ្មីៗ ជាមួយបណ្តាក្រុមហ៊ុនអាមេរិកនានា គឺជាលទ្ធភាពផ្សេងៗទៀតសម្រាប់សហរដ្ឋអាមេរិកក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តដ៏មោះមុតរបស់ កម្ពុជាក្នុងការធ្វើឱ្យទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកកាន់តែស៊ីជម្រៅថែមទៀត ក៏ដូចជាការលើកកម្ពស់ភាពជាដៃគូអាស៊ាន-អាមេរិក ឆ្ពោះទៅកាន់កម្រិតថ្មីមួយទៀត ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក ផលប្រយោជន៍រួម និងការជឿទុកចិត្តគ្នាទៅវិញទៅមក។

កិច្ចប្រជុំបានឯកភាពគ្នាអនុម័តផែនការសកម្មភាពថ្មី ឆ្នាំ២០២០-២០២៥ ដែលបានដាក់ចេញនូវបណ្តាសកម្មភាព និងវិស័យយុទ្ធសាស្ត្រជាច្រើន ដើម្បីកំណត់ទិសដៅកិច្ចសហប្រតិបត្តិការអនាគតរវាងភាគីទាំងពីរ សម្រាប់រយៈពេល៥ឆ្នាំខាងមុខទៀត។

## <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-កាណាដា</u>

កិច្ចប្រជុំបានសង្កត់ធ្ងន់អំពីសមិទ្ធិផលនៃកិច្ចសហប្រតិបត្តិការដែលសម្រេចបានកន្លងមក និងបានពិភាក្សាអំពីមធ្យោបាយដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ សម្រាប់ផលប្រយោជន៍រួម។ កិច្ចប្រជុំបានកត់សម្គាល់ដោយសោមនស្ស ក្នុងការអនុវត្តដោយពេញលេញនូវផែនការសកម្មភាព ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍រួមនៃការលើកកម្ពស់ភាពជាដៃគូអាស៊ាន-កាណាដា (២០១៦-២០២០) និងអនុម័តផែនការសកម្មភាពថ្មី (២០២១-២០២៥)។

ប្រទេសសមាជិកអាស៊ានបានស្វាគមន៍ការប្តេជ្ញាចិត្តរបស់កាណាដា ក្នុងការពង្រឹងភាពជាដៃគូជាមួយអាស៊ាន ជាពិសេស ក្នុងវិស័យផ្សេងៗដូចជា សេដ្ឋកិច្ច និងពាណិជ្ជកម្ម ការស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ការលើកកម្ពស់ការតភ្ជាប់រវាងប្រជាជន និងប្រជាជន ក៏ដូចជាការកសាងសមត្ថភាព។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការបញ្ចប់កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា ក្នុងគោលបំណងដើម្បីជំរុញកំណើនសេដ្ឋកិច្ចសម្រាប់តំបន់ទាំងពីរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើការណាជាជួយផ្តល់ការគាំទ្របន្ថែមទៀតដល់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) នៅរាជធានីភ្នំពេញ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានកោតសរសើរការណាជា ក្នុងការពិចារណាការលើកកម្ពស់តួនាទីស្ត្រី ជាអាទិភាពមួយ ក្នុងចំណោមអាទិភាពនានានៃកិច្ចសហប្រតិបត្តិរបស់ខ្លួនជាមួយអាស៊ាន និងបានលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀត ខាងផ្នែកថែរក្សាសន្តិភាព ការកសាងសន្តិភាព ក៏ដូចជាការដោះស្រាយជម្លោះជាពិសេស លើរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS)។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អូស្ត្រាលី

កិច្ចប្រជុំបានពិនិត្យឡើងវិញលើកិច្ចសហប្រតិបត្តិការ និងបានធ្វើការផ្លាស់ប្តូរយោបល់ស្តីពីកិច្ចសហ-ប្រតិបត្តិការអនាគត ជាពិសេសកិច្ចសហប្រតិបត្តិការក្រោយកូវីដ-១៩។ កិច្ចប្រជុំបានកត់សម្គាល់ដោយសោមនស្សនូវវឌ្ឍនភាពដែលសម្រេចបាន ក្នុងការអនុវត្តផែនការសម្មភាពអាស៊ាន-អូស្ត្រាលី(២០១៥-២០១៩)។

ដោយទទួលស្គាល់នូវកិច្ចសហប្រតិបត្តិការប្រកបដោយខ្លឹមសាររវាងភាគីទាំងពីរ អាស៊ានបានគាំទ្រឱ្យមានការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលីប្រចាំឆ្នាំ ដែលនឹងចូលជាធរមាន នៅក្នុងឆ្នាំ២០២១ខាងមុខ។

កម្ពុជាបានទទួលស្គាល់ឯកសារទស្សនាទានរបស់អូស្ត្រាលី ស្តីពីជម្រើសនានា សម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការអាស៊ាន-អូស្ត្រាលី ក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩ និងការស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ និងបានថ្លែងអំណរគុណអូស្ត្រាលី ដែលបានរួមចំណែកយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ជាពិសេសចំពោះកម្ពុជា តាមរយៈគម្រោងកែលម្អសមភាព និងគុណភាពសុខភាព (H-EQIP)។ កម្ពុជាបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការអប់រំ ការផ្លាស់ប្តូរប្រជាជននិងប្រជាជន និងបានលើកទឹកចិត្តឱ្យអូស្ត្រាលីផ្តល់អាហារូបករណ៍បន្ថែមទៀត ដោយពិចារណាលើសេចក្តីត្រូវការជាក់លាក់របស់ប្រទេសសមាជិកអាស៊ាននីមួយៗ។ ការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាពជាពិសេសសហគ្រិនភាពស្ត្រី និងការអភិវឌ្ឍភាពជាអ្នកដឹកនាំឌីជីថល ក៏មានសារៈសំខាន់ខ្លាំងផងដែរ ចំពោះការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយភាពរឹងមាំ និងបរិយាប័ន្ន ក្រោយវិបត្តិជំងឺកូវីដ-១៩។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-នូវែលហ្សេឡង់

កិច្ចប្រជុំត្រូវបានដឹកនាំរួមគ្នាដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលបច្ចុប្បន្នជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលហ្សេឡង់ (២០១៨-២០២១) និង**ឯកឧត្តម គ្រីស ស៊ីវ** អនុរដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មនូវែលហ្សេឡង់។

កិច្ចប្រជុំបានធ្វើការកត់សម្គាល់ដោយក្តីសោមនស្សនូវវឌ្ឍនភាពប្រកបដោយខ្លឹមសារនៃភាពជាដៃគូ អាស៊ាន-នូវែលហ្សេឡង់ ហើយរីករាយនឹងសមិទ្ធិផលដែលសម្រេចបាន ក្នុងការអនុវត្តដោយពេញលេញនូវផែនការសកម្មភាពដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-នូវែលហ្សេឡង់ ២០១៦-២០២០ និងយុទ្ធសាស្ត្រគន្លឹះទាំងពីរ គឺ «ប្រជាជន និងវិបុលភាព» ។ កិច្ចប្រជុំបានអនុម័តផែនការសកម្មភាពថ្មី (២០២១-២០២៥) ដែលសង្កត់ធ្ងន់លើវិស័យកិច្ចសហប្រតិបត្តិការទាំងបួនគឺ «ប្រជាជន វិបុលភាព សន្តិភាព និងភពផែនដី»។

កិច្ចប្រជុំក៏ទន្ទឹងរង់ចាំផងដែរនូវការបញ្ចប់កិច្ចចរចា និងការរៀបចំកិច្ចព្រមព្រៀងសេវាកម្មអាកាសចរ អាស៊ាន-នូវែហ្សេឡង់ ដែលប្រកបដោយគុណភាពខ្ពស់។

ដោយសារបច្ចុប្បន្ន កម្ពុជាគឺជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលហ្សេឡង់ និងជាសហប្រធាននៃកិច្ចប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងសុន្ទរកថារួមតំណាងអាស៊ាន ដែលសង្កត់ធ្ងន់អំពីសមិទ្ធិផល និងសារៈសំខាន់នៃភាពជាដៃគូយុទ្ធសាស្ត្រយូរអង្វែងរវាងអាស៊ាន និងនូវែលហ្សេឡង់។ ចំពោះគោលដៅអនាគតអាស៊ាន-នូវែលហ្សេឡង់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានជូនមតិថា កិច្ចសហប្រតិបត្តិការបន្ថែមទៀតគួរតែធ្វើឡើងក្នុងវិស័យទាំងឡាយដូចជាសេដ្ឋកិច្ចឌីជីថល ពាណិជ្ជកម្មអេឡិចត្រូនិក ការអភិវឌ្ឍទីក្រុងឆ្លាត ទេសចរណ៍ កិច្ចសហប្រតិបត្តិការសន្តិសុខអ៊ីនធើ-នេត ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិស័យកសិកម្ម សន្តិសុខស្បៀង និងសុវត្ថិភាពស្បៀងអាហារ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើសុំការគាំទ្របន្ថែមទៀតដល់មជ្ឈមណ្ឌល ARMAC ផងដែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់កម្ពុជា ដើម្បីធ្វើការប្រកបដោយបុរេសកម្មជាមួយប្រទេសសមាជិកអាស៊ាន និងនូវែលហ្សេឡង់ ក្នុងការរៀបចំកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំអាស៊ាន-នូវែលហ្សេឡង់ ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៤៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវែលហ្សេឡង់ នៅចុងឆ្នាំ ២០២០នេះ។

**<u>កិច្ចប្រជុំរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៣ ជាមួយតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស</u>**

កិច្ចប្រជុំបានកត់សំគាល់របាយការណ៍ប្រចាំឆ្នាំ របស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) ឆ្នាំ ២០២០ និងបានអនុម័តលើផែនការការងាររយៈពេល៥ឆ្នាំ របស់ AICHR ឆ្នាំ២០២១-២០២៥ និងថវិកាសម្រាប់កម្មវិធីអាទិភាព/ សកម្មភាពរបស់ AICHR ឆ្នាំ ២០២១ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានចូលរួមជាមួយរដ្ឋមន្ត្រីការបរទេសដទៃទៀតកោតសរសើរចំពោះ AICHR ចំពោះវឌ្ឍនភាពគួរឱ្យកត់សំគាល់ក្នុងការជំរុញ និងការការពារសិទ្ធិមនុស្សនៅមូលដ្ឋាននៅក្នុងតំបន់អាស៊ាន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា សិទ្ធិមនុស្សគួរត្រូវបានស្រាយ និង

ទទួលយកក្នុងលក្ខណៈគ្រប់ជ្រុងជ្រោយ ប្រកបដោយភាពស្មោះត្រង់ សង្គតិភាព និងមិនប្រើស្តង់ដារទ្វេ។ សិទ្ធិមនុស្សមិនគួរត្រូវបានប្រើប្រាស់ជាឧបករណ៍បម្រើភូមិសាស្ត្រនយោបាយ ដើម្បីបិទបាំងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យណាមួយនោះឡើយ។ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចពិភាក្សាយុវជនស្តីពីសិទ្ធិមនុស្សឆ្នាំ ២០២១ នៅទីក្រុងភ្នំពេញ។

<u>**កិច្ចពិភាក្សាថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីការពង្រឹងតួនាទីស្ត្រីដើម្បីសន្តិភាព និងសន្តិសុខប្រកបដោយចីរភាព**</u>

កិច្ចប្រជុំបានកត់សម្គាល់ ពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់អាស៊ាន ដើម្បីជំរុញការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិលេខ ១៣២៥ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ដែលឆ្នាំនេះជាខួបទី ២០ នៃការអនុម័តសេចក្តីសម្រេចនេះ។ កិច្ចប្រជុំក៏បានពិភាក្សាពីវិធីដើម្បីលើកកម្ពស់តួនាទី និងសកម្មភាពរួមគ្នារបស់ស្ត្រីអាស៊ាន ដើម្បីពង្រឹងសន្តិភាព សន្តិសុខ និងវិបុលភាពប្រកបដោយចីរភាពក្នុងតំបន់ និងបានបញ្ជាក់ជាថ្មីអំពីតួនាទីដ៏សំខាន់របស់ស្ត្រី មិនត្រឹមតែក្នុងកិច្ចការសន្តិសុខ-នយោបាយប៉ុណ្ណោះទេ ថែមទាំងក្នុងវិស័យសង្គម-សេដ្ឋកិច្ចផងដែរ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានរំលេចពីភាពម៉ឺងម៉ាត់របស់កម្ពុជាក្នុងការអនុវត្តរបៀបវារៈស្ត្រី ដើម្បីសន្តិភាព និងសន្តិសុខ ក្នុងនាមជាប្រទេស ដែលធ្លាប់ឆ្លងកាត់ជាក់ស្តែងនូវទុក្ខវេទនាដែលសង្គ្រាម និងជម្លោះ បានបង្កឡើងដល់ប្រជាជន និងប្រទេសជាតិ ជាពិសេសលើស្ត្រី និងកុមារ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានលើកឡើងពីការចូលរួមជាក់ស្តែងរបស់កម្ពុជាលើរបៀបវារៈស្ត្រី ដើម្បីសន្តិភាព និងសន្តិសុខ តាមរយៈកំណើននៃការចូលរួមរបស់ស្ត្រីកម្ពុជា ក្នុងសកម្មភាពមនុស្សធម៌ ការដោះមីន និងប្រតិបត្តិការរក្សាសន្តិភាព នៅតាមតំបន់ផ្សេងៗនៅលើពិភពលោក។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបកិច្ចប្រជុំថា កម្ពុជានឹងរៀបចំកិច្ចប្រជុំស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នាឱកាសនៃកិច្ចប្រជុំកំពូលអាស៊ី - អឺរ៉ុបលើកទី១៣ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការលើកស្ទួយស្ត្រីរវាងតំបន់ទាំងពីរ៕

ថ្ងៃសុក្រ ៩រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០២០